CCIM

# របាយការណ៍សង្ខេប
# នៃការស្រាវជ្រាវអំពីសេរីភាពបញ្ចេញមតិ លើប្រព័ន្ធព័ត៌មានវិទ្យា និង ការចូលរួមនយោបាយ នៅកម្ពុជា

មេសា ២០១៥

ដោយជំនួយសប្បុរសធម៌ពី ៖

FREEDOM HOUSE

The International Republican Institute IRI advancing democracy worldwide

USAID ជំនួយពីពលរដ្ឋអាមេរិក

បោះពុម្ពផ្សាយដោយ ៖ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

សម្រាប់ព័ត៌មានបន្ថែម

អាសយដ្ឋាន ៖ ផ្ទះលេខ ១៤អា ផ្លូវ ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ភ្នំពេញ
វិបសាយ ៖ www.ccimcambodia.org
អ៊ីម៉ែល ៖ communications@ccimcambodia.org
លេខទូរស័ព្ទ ៖ ០២៣ ៧២៦ ៨៤២

CC BY ND

# របាយការណ៍សង្ខេបនៃការស្រាវជ្រាវ ការយល់ឃើញ អំពីសេរីភាពបញ្ចេញមតិលើប្រព័ន្ធព័ត៌មានវិទ្យា និង ការចូលរួមនយោបាយ

ដោយ៖ Amanda King | Jayson W. Richardson | John B. Nash

រៀបរៀងដោយ៖ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

ដោយជំនួយសប្បុរសធម៌ពី ៖

USAID

Freedom House

និង the International Republican Institute.

*សេចក្តីបញ្ជាក់៖ គំនិត និងមតិយោបល់របស់អ្នកនិពន្ធក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីមតិយោបល់ និងគំនិត*
*United States Agency for International Development or the United State Government,*
*the International Republican Institute ឬ Freedom House ឡើយ។*

# សេចក្តីសង្ខេប

ការប្រើប្រាស់អ៊ីនធើណែតនៅកម្ពុជាកំពុងតែកើនឡើងក្នុងអត្រាមួយយ៉ាងឆាប់រហ័ស ដោយក្នុងឆ្នាំ២០១៤ អ្នកប្រើប្រាស់អ៊ីនធើណែតកម្ពុជា ស្ទុះឡើង៤២,៧%។ បច្ចុប្បន្នអត្រានេះឡើងដល់ ២៥% នៃប្រជាជនសរុប ឬប្រហែល៣,៨លាននាក់ ច្រើនជាងឆ្នាំ២០១៣ ដែលមានតែ ២,៧ លាននាក់ប៉ុណ្ណោះ។ ជាការឆ្លើយតបទៅនឹងកំណើនអ្នកប្រើប្រាស់អ៊ីនធើណែត និងដើម្បីបង្ហាញពីក្តីកង្វល់របស់រដ្ឋាភិបាលជុំវិញ ការទទួលបានព័ត៌មានពីប្រព័ន្ធព័ត៌មានវិទ្យាដោយគ្មានការត្រួតពិនិត្យនៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងនូវវិធានការមួយចំនួនដើម្បីឃ្លាំមើលនិងគ្រប់គ្រងអ៊ិនធើណែត។ វិធានការដើម្បី គ្រប់គ្រងនិងតាមដានសកម្មភាពលើប្រព័ន្ធបច្ចេកវិទ្យាទាំងនោះរួមមាន សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យា ដែលកាលនោះរងការរិះគន់ជាសកល (ឥឡូវត្រូវបានទុកចោលជាផ្លូវការហើយ) គំរោងដម្លើងឧបករណ៍តាមដានលើក្រុមហ៊ុនដែលផ្តល់សេវាអ៊ិនធើណែត ក្នុងប្រទេស និងការបង្កើតក្រុមប្រយុទ្ធប្រឆាំងនិងបទឧក្រិដ្ឋលើប្រព័ន្ធព័ត៌មានវិទ្យាដើម្បីឃ្លាំមើលគេហទំព័រ ជាពិសេសគឺបណ្តាញ សង្គម ហ្វេសប៊ុក ពីការផ្សាយព័ត៌មានដែលអាចមានលក្ខណៈមិនពិតអំពីរដ្ឋាភិបាល។

ប៉ុន្តែ ការសន្ទនានានាចុងក្រោយអំពីសិទ្ធិ និងការគ្រប់គ្រងអ៊ីនធើណែតកម្ពុជាជួបប្រទះនឹងបញ្ហាដោយសារកង្វះទិន្នន័យជុំវិញឥរិយាបទនៃអ្នកប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅកម្ពុជា និងការយល់ឃើញរបស់គេលើឥទ្ធិពលនៃអ៊ីធើណែត និងបញ្ហានៃការកំរិតនៃការប្រើប្រាស់អ៊ីនធើណែតក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ នយោបាយ និងសង្គម។

គំរោងស្រាវជ្រាវនេះមានបំណងដោះស្រាយកង្វះព័ត៌មាន អំពីការប្រើប្រាស់អ៊ីធើណែតដោយការស្ទង់មតិអ្នក ប្រើប្រាស់នៅកម្ពុជាលើបញ្ហាសំខាន់ៗមួយចំនួន ដើម្បីផ្តល់ព័ត៌មានបន្ថែមទៀតសំរាប់ការពិភាក្សាអំពីអនាគតអ៊ីនធើណែត ក្នុងប្រទេសកម្ពុជា។ ក្នុងការស្រាវជ្រាវយើងបានប្រើប្រាស់ទំរង់សំរាប់ទទួលការឆ្លើយតបបីរួមគ្នា ហើយបានធ្វើការស្ទង់មតិលើអ្នកប្រើស្មាតហ្វូនចំនួន៨៩៥នាក់ តាមរយៈទូរស័ព្ទគេតែម្តង។ របាយការណ៍សង្ខេបនៃការស្រាវជ្រាវនេះ នឹងផ្តល់ព័ត៌មានដែលបានដកស្រង់ចេញពីការសិក្សានេះ ដោយមានការចងក្រង និងរៀបរៀងឡើងដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)។

## ការរកឃើញសំខាន់ៗ

- ៧៧.៧% នៃអ្នកឆ្លើយតប បានអោយដឹងថា ទូរស័ព្ទស្មាតហ្វូនរបស់ពួកគេ គឺជាឧបករណ៍ដែល គេចូលចិត្តយកទៅប្រើអ៊ីនធើណែត។
- ប្រជាជនកម្ពុជាយល់ថាអ៊ីនធើណែតមានប្រយោជន៍សំរាប់បញ្ហាផ្ទាល់ខ្លួន អាជីពនិងការចូលរួមក្នុងសង្គម។ ៧៥% នៃអ្នកឆ្លើយតបយល់ស្របថា អ៊ីនធើណែតឱ្យការងាររបស់គេមានភាពងាយស្រួលជាងមុន មិនតែប៉ុណ្ណោះ វាថែមទាំងជួយក្នុងការសិក្សា និងធ្វើឱ្យពួកគេទទួលបានព័ត៌មានដែលមិនអាចរកបានតាមវិធីផ្សេងទៀតផង។
- ការទិញទំនិញនិងការទូទាត់ប្រាក់តាមប្រព័ន្ធព័ត៌មានវិទ្យា មិនមែនជាសកម្មភាពពេញនិយមក្នុងប្រទេសកម្ពុជា។ ប្រហែល មួយភាគបីនៃអ្នកឆ្លើយតបបានឱ្យដឹងថាគេធ្លាប់ទិញ លក់លើប្រព័ន្ធអេឡិចត្រូនិក។
- ភាគច្រើននៃអ្នកប្រើប្រាស់អ៊ីនធើណែតកម្ពុជា (៦២.៧%) មានអារម្មណ៍ថា មានសេរីភាព "យ៉ាងខ្លាំង" ឬ "ខ្លះៗ" ក្នុងការបង្ហាញពីគំនិតលើប្រព័ន្ធ ព័ត៌មានវិទ្យាដោយគ្មានការភ័យខ្លាច។
- ក្នុងចំណោម អ្នកឆ្លើយតបដែលបាននិយាយថាពួកគេមានការភ័យព្រួយ "ខ្លះៗ" ឬ "យ៉ាងខ្លាំង" ទៅលើការបញ្ចេញមតិលើប្រព័ន្ធព័ត៌មានវិទ្យា ភាគច្រើបារម្ភអំពីការគំរាមកំហែងផ្លូវច្បាប់ (៦៥.៦%) ការបំពានផ្លូវកាយ (៣៦.៨%) និងការគំរាមកំហែងផ្នែកសេដ្ឋកិច្ច(៣០.៦%)។
- កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការឃ្លាំមើល សកម្មភាពលើប្រព័ន្ធព័ត៌មានវិទ្យា អាចមានឥទ្ធិពលធ្វើឱ្យសេរីភាពបញ្ចេញ មតិធ្លាក់ចុះ ដោយភាគច្រើននៃអ្នកប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា(៨៨.៤%) និយាយថា ពួកគេនឹងមិនមានអារម្មណ៍ថាមានសេរីភាពក្នុងការបញ្ចេញមតិឡើយ ប្រសិនបើមានការឃ្លាំមើលមែននោះ។
- ថ្មីៗនេះ ភាគច្រើននៃអ្នកឆ្លើយតប (៦២.៧%) មានអារម្មណ៍ថាមានសេរីភាព "យ៉ាងខ្លាំង" ឬ "ខ្លះៗ" ក្នុងការបញ្ចេញមតិដោយមិនមានការភ័យខ្លាច ។
- ក្រៅពីអ្នកឆ្លើយតប បួននាក់ អ្នកដទៃបានឱ្យដឹងពួកគេមានគណនីហ្វេសប៊ុក។ លើសពីនេះទៅទៀត បួនលើប្រាំនាក់នៃប្រជាជនកម្ពុជា បើកមើលហ្វេសប៊ុករបស់ខ្លួនច្រើនដងក្នុងមួយថ្ងៃ។

# ការឆ្លុះបញ្ចាំង និង អនុសាសន៍

## *មានការចាំបាច់អោយមានការពិភាក្សា និងអប់រំអំពីសិទ្ធិអ៊ីនធើណែត ការតាមដាន ឯកជនភាព និងបញ្ហាដទៃទៀតដែលត្រូវមានក្នុងច្បាប់អ៊ីនធើណែត។*

អ្នកឆ្លើយតបបានគាំទ្រយ៉ាងខ្លាំងលើសេរីភាពបញ្ចេញមតិតាមប្រព័ន្ធបច្ចេកវិទ្យា ក្នុងនោះដែរក៏គាំទ្រឱ្យមានការរឹតត្បិតលើខ្លឹមសារនៃការផ្សាយទាំងឡាយណាដែលអសីលធម៌។ មានការចាំបាច់អោយមានការពិភាក្សាកាន់តែស៊ីជម្រៅបន្ថែមទៀតអំពីសិទ្ធិអ៊ីនធើណែត និងការកំរិតដ៏សមស្របដើម្បីអោយមានការទទួលយកទាំងអស់គ្នាក្នុងបរិបទប្រទេសកម្ពុជា។ អ្នកឆ្លើយតបទាំងអស់មានអារម្មណ៍ថាពួកគេដឹងយ៉ាងច្បាស់ពីសេរីភាពបញ្ចេញមតិ និងសេរីភាពអ៊ីនធើណែតហើយតួលេខនេះមិនមានលក្ខណៈខុសគ្នាខ្លាំងរវាងអ្នកប្រើអ៊ីនធើណែតដែលបានអានពីសកម្មភាពរដ្ឋាភិបាលក្នុងការឃ្លាំមើល និងគ្រប់គ្រងអ៊ីនធើណែត និងអ្នកដែលមិនបានអានព័ត៌មានអំពីបញ្ហានេះ។ ដូច្នេះទិន្នន័យនេះធ្វើឱ្យយើងដឹងថា យើងត្រូវការពិនិត្យមើលឡើងវិញឱ្យបានស៊ីជម្រៅ និងឯករាជ្យថែមទៀតអំពីបណ្តាញផ្សព្វផ្សាយ ព័ត៌មានជាភាសាខ្មែរក្នុងប្រទេស ដើម្បីផ្សព្វផ្សាយមតិនិងការពិភាក្សាផ្សេងៗ រួមទាំងមតិយោបល់ពីអ្នកជំនាញ បច្ចេកទេស សន្តិសុខ និងសិទ្ធិមនុស្ស។

## *ដៃគូអភិវឌ្ឍកម្ពុជាត្រូវផ្តល់អទិភាពដល់ការប្រើអ៊ីនធើណែតសំរាប់ការអភិវឌ្ឍន ជាពិសេសការអភិវឌ្ឍទាំងឡាយណាដែលយុវជនជាគោលដៅ។*

សន្ទស្សន៍នៃអ្នកឆ្លើយតបជាយុវជនក្នុងការស្ទង់មតិ ហើយនិងការផ្សាភ្ជាប់រវាងយុវជន និងព័ត៌មានវិទ្យា ដូចជា ទូរស័ព្ទស្មាតហ្វូន បង្ហាញពីលទ្ធភាពសំរាប់កម្ពុជាក្នុងការអភិវឌ្ឍប្រទេស និងការប្រតិបត្តិសិទ្ធិមនុស្សដែលប្រទេសនេះទើបស្វែងរកឃើញ។ ដៃគូអភិវឌ្ឍអន្តរជាតិនិងដៃគូអភិវឌ្ឍក្នុងស្រុកគួរធ្វើការរួមគ្នាដើម្បីធានាថា បច្ចេកវិទ្យាថ្មីៗទាំងនេះត្រូវបានប្រើប្រាស់ដើម្បីបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ នានាក្នុងស្រុក។

## *ចាំបាច់ត្រូវមានការពង្រីកការអប់រំឱ្យមានការយល់ដឹងពីប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយអនឡាញ។*

ទោះបីភាគច្រើននៃអ្នកឆ្លើយតបបានឱ្យដឹងពីការប្រើប្រាស់អ៊ីនធើណែតដើម្បី ទទួលបានព័ត៌មាននិងដំណឹងផ្សេងៗក៏ដោយ អ្នកចូលរួមខ្លះបានបង្ហាញពីការ មិនទុកចិត្តលើព័ត៌មានទាំងអស់ដែលគេអានលើអ៊ីនធើណែត។ បើត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាដូចអ្វីដែលកំពុងពិភាក្សា ការអប់រំឱ្យយល់ដឹងពីប្រព័ន្ធផ្សព្វផ្សាយ នឹងជួយសិស្ស និស្សិតឱ្យយល់ពីភាពខុសគ្នារវាងពាក្យចចាមអារាម និងព័ត៌មានអនឡាញ ហើយថែមទាំងបង្កើនជំនាញក្នុងការគិតបែបវិភាគលើព័ត៌មានដែលគេទទួលបានអនឡាញទៀតផង។

***វិធានការ លើកទឹកចិត្តឲ្យប្រើប្រាស់អ៊ីធើណែតតាមទូរស័ព្ទដៃ ឬឧបករណ៍ចល័ត មានសារសំខាន់ណាស់សំរាប់អ្នកប្រើប្រាស់អ៊ីនធើណែតកម្ពុជា។***

ដើម្បីទៅដល់អ្នកប្រើប្រាស់ឱ្យបានចំនួនច្រើនបំផុត អ្នកវិនិយោគ និងអង្គការក្រៅរដ្ឋាភិបាលនៅទាំងអស់ក្នុងទីផ្សារកម្ពុជាគួរធានាថា វេបសាយ និងសេវាអេឡិចត្រូនិកដទៃ ទៀតអាចប្រើបានយ៉ាងងាយស្រួលតាមរយៈទូរស័ព្ទនិងឧបករណ៍ចល័ត។ ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនោះគឺ ផ្តល់ឱកាសយ៉ាងសំបើមឱ្យមានកំណើនកម្មវិធីលើប្រព័ន្ធឧបករណ៍ចល័តនិងការទិញ លក់ តាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេស។ មានភាគរយទាបនៃអ្នកឆ្លើយតបដែលបានឱ្យដឹងពីការប្រើអិនធើណែត ក្នុងការទិញទំនិញ បង់ប្រាក់ ឬគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេអនឡាន បើទោះ ជាមានការរីកសាយភាយសេវាកម្មហិរញ្ញវត្ថុអនឡាញតាមរយៈធនាគារក្នុងស្រុកក៏ដោយ។ ទិន្នន័យនេះធ្វើឱ្យយើងដឹងថាអ្នកប្រើប្រាស់អ៊ីនធើណែតកម្ពុជាខ្វះជំនឿលើសុវត្ថិភាពហិរញ្ញវត្ថុរបស់គេលើប្រព័ន្ធព័ត៌មានវិទ្យា។

***សេរីភាពបញ្ចេញមតិលើប្រព័ន្ធព័ត៌មានវិទ្យាត្រូវការ ការការពារពីច្បាប់កម្ពុជា។***

ការបញ្ចេញមតិលើប្រព័ន្ធព័ត៌មានវិទ្យា ដូចគ្នានឹងការបញ្ចេញមតិតាមមធ្យោបាយផ្សេងៗទៀតដែលបានទទួលការការពារក្រោមច្បាប់អន្តរជាតិក្នុងនាមសិទ្ធិមនុស្សជាមូលដ្ឋាន។ បើទោះជាភាគច្រើននៃប្រជាជនកម្ពុជាមានអារម្មណ៍ ថាពួកគេមានសេរីភាពក្នុងការបញ្ចេញមតិអនឡាញក៏ដោយប្រជាជនកម្ពុជាខ្លះនៅតែ មានការភ័យខ្លាច "ខ្លះៗ" (១៤.៣%) ឬ "យ៉ាងខ្លាំង" (១.៦%) ក្នុងការបញ្ចេញមតិអនឡាញ។ រាជរដ្ឋាភិបាល កម្ពុជាគួរទទួលស្គាល់និងធានាការពារសិទ្ធិក្នុងការបញ្ចេញមតិអនឡាញ ជាផ្នែកមួយនៃការធានាដោយរដ្ឋធម្មនុញ្ញស្តីពីសេរីភាពក្នុងការបញ្ចេញមតិដែលមានស្រាប់ ឬអាចជាផ្នែកមួយនៃច្បាប់អិនធើណែត ដូចជាសំណើរសេចក្តីព្រាងស្តីពីសេរីភាពអិនធើណែតនៅកម្ពុជា។

***រាជរដ្ឋាភិបាលកម្ពុជាគួរ បង្កើនបរិមាណនៃព័ត៌មានសាធារណៈអនឡាញ។***

ដោយសារតែការប្រើប្រាស់ អ៊ីនធើណែតបន្តកើនឡើង ហើយប្រជាជនកម្ពុជាច្រើនឡើងៗងាកមកប្រើអ៊ីនធើណែតដើម្បីទទួលបានព័ត៌មានអំពីច្បាប់ គោលនយោបាយ និងគណបក្សនយោបាយ រដ្ឋាភិបាលគួរធ្វើយ៉ាងណាឱ្យព័ត៌មានសាធារណមានផ្សាយជាសាធារណៈអនឡាញ។រដ្ឋាភិបាលគួរពិចារណាដាក់បញ្ចូលការបង្ហាញព័ត៌មានសាធារណៈ អនឡាញ ទៅក្នុងច្បាប់សិទ្ធិទទួលបានព័ត៌មានដែលបាននឹងកំពុងធ្វើសេចក្តីព្រាង។

## អវសាន

ប្រជាជនកម្ពុជាមិនអាចដើរតួនាទី សកម្មក្នុងសង្គមបានឡើយ ប្រសិនបើពួកគេមិនបានទទួលព័ត៌មានត្រឹមត្រូវ និងគ្រប់គ្រាន់។ យ៉ាងណាមិញ គណនីយភាព និងតម្លាភាពរបស់រដ្ឋាភិបាលមានសារសំខាន់យ៉ាងខ្លាំងសំរាប់ប្រជាជនកម្ពុជា។ ភាគច្រើននៃអ្នកប្រើប្រាស់ទូរស័ពដែលមានភ្ជាប់អ៊ីនធើណែត មានអារម្មណ៍ថាអ៊ីនធើណែតគឺយន្តការ ដើម្បីលើកកំពស់ខ្លួនវិជ្ជាជីវៈ និងតួនាទីពលរដ្ឋ។ មានតែ សេរីភាពអ៊ិនធើណែត ដោយគ្មានការឃ្លាំមើលប៉ុណ្ណោះ ដែលអាចឱ្យប្រជាពលរដ្ឋបញ្ចេញមតិដោយសេរី និងប្រើប្រាស់អ៊ីនធើណែតជាឧបករណ៍ដើម្បីទទួលបានព័ត៌មានអំពីពិភពលោក ជាតិ សាសន៍ និងវប្បធម៌របស់ខ្លួន។

## ការថ្លែងអំណរគុណ

របាការណ៍នេះអាចសំរេចទៅបានដោយដោយការគាំទ្រង៍សប្បុរសពីអង្គការ Freedom House ( FH ) International Republican Institute ( IRI ) និង USAID ។ ការស្រាវជ្រាវនេះរៀបរៀងឡើង និងវិភាគដោយបុគ្គលិក CCIM ដោយមានការប្រឹក្សាយោបល់ជាមួយបណ្ឌិត Jayson w. Richardson និង Jonh B. Nash មកពីសកលវិទ្យាល័យ Kentucky។

CCIM ក៏ សូមថ្លែងអំណរគុណដល់អ្នកបានចំណាយពេលចូលរួមក្នុងការស្ទង់មតិនេះ ព្រមទាំងក្រុមពិភាក្សា ហើយនឹងអ្នកដទៃទៀតដែលបានចំណាយ ពេលវេលាបញ្ជូនការស្ទង់មតិនេះបន្តតាមក្នុងដំណាក់កាលធ្វើតេស្តសាកល្បង។

*ដើម្បីអានរបាយការណ៍ពេញលេញនៃការស្រាវជ្រាវនេះសូមចូលទៅកាន់គេហទំព័រ ៖ www.ccimcambodia.org/reports*